**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គម**

លេខ :......១០/២១......ប.ស.ស.

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតក្រុមការងារចំពោះកិច្ចសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាព សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៧១៣ អនក្រ.តត ចុះថ្ងៃទី៣០ ខែឧកក្កដា ឆ្នាំ២០២០ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី១
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ/បក ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ៣៥៦ អនក្រ.តត ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី១
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ , ០២៣ ៩៩ ៩២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

## **សម្រេច**

**ប្រការ១ ..**

ត្រូវបានបង្កើត "ក្រុមការងារសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាព សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" សំដៅពិនិត្យលទ្ធភាព កែសម្រួលកញ្ចប់តាវកាលិកថែទាំសុខភាពសម្រាប់សមាជិក ប.ស.ស. ក្នុងស្ថានភាពនៃការរីករាល ដាលជំងឺកូវីដ-១៩ ឲ្យមានភាពសមស្របនឹងអត្រាភាគទានដែលត្រូវកែសម្រួល។

**ក. សមាសភាពក្រុមការងារនេះមានដូចខាងក្រោម៖**

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ុក សមវិទ្យា** | អគ្គនាយកបេឡាជាតិសន្តិសុខសង្គម | ប្រធាន |
| ២-លោកជំទាវ **ឆាត់ ឡេងចាន់ឆាយ៉ា** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៣-ឯកឧត្តម **ទិន សុខឃួន** | តំណាងក្រសួងមុខងារសាធារណៈ | សមាជិក |
| ៤-ឯកឧត្តមវេជ្ជ.**ឡូ វាសនាគីរី** | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៥-ឯកឧត្តម **អៀម គន្ធឌី** | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦-ឯកឧត្តម **សៅ ផល្លា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោកឧកញ៉ាបណ្ឌិត **ណាង សុធី** | តំណាងនិយោជក | សមាជិក |
| ៨-លោកឧកញ៉ា **សុខ ពិសិដ្ឋ** | តំណាងនិយោជក | សមាជិក |
| ៩-លោក **អាត់ ធន់** | តំណាងសមាជិក ប.ស.ស. | សមាជិក |
| ១០-ឯកឧត្តម **ហេង ប៊ុនឈុន** | តំណាងសមាជិក ប.ស.ស. | សមាជិក |
| ១១-លោកសាស្ត្រាចារ្យរង **ប៊ុន សំណាង** | ប្រធានការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញប្បទានសុខាភិបាលនៃនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល | សមាជិក |
| ១២-លោក **ភាំង ម៉ូនីកា** | អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | សមាជិក |
| ១៣-លោក **លូ ម៉េង** | ប្រធានសហព័ន្ធទេសចរណ៍កម្ពុជា | សមាជិក |
| ១៤-លោកស្រី **អៀង ម៉ារីយ៉ា** | ប្រធានរដ្ឋបាលនិងធនធានមនុស្សនៃសមាគមធនាគារកម្ពុជា | សមាជិក |
| ១៥-លោក **ឈិត សិទ្ធិរ៉ា** | នាយករងផ្នែកវិភាគនិងការយល់ដឹងអំពីអតិថិជន | សមាជិក |

**ខ. ក្រុមការងារនេះមានតួនាទីនិងភារកិច្ចដូចតទៅ៖**

- សិក្សាស្រាវជ្រាវ និងកំណត់កញ្ចប់ថ្លៃចំណាយព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់អ្នកជំងឺកូវីដ-១៩ ដែលជាសមាជិក ប.ស.ស.
- សិក្សាស្រាវជ្រាវ និងកំណត់កញ្ចប់ថ្លៃសេវាបង្ការសុខភាពចំពោះជំងឺកូវីដ-១៩

- រៀបចំទិន្នន័យតារកាលិកសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ដំណើរការវិភាគហានិភ័យហិរញ្ញវត្ថុ
- សិក្សាស្រាវជ្រាវ និងវិភាគបញ្ហាឱនភាពថវិកាផ្នែកថែទាំសុខភាពធៀបនឹងអត្រាភាគទាននាពេលបច្ចុប្បន្ន
- កំណត់បញ្ហាអាទិភាពដើម្បីធ្វើការកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាព
- កំណត់ចំនួនអត្រាភាគទានដែលត្រូវស្នើសុំកែសម្រួល
- ប្រជុំត្រួតពិនិត្យសម្រេចលើរបាយការណ៍សិក្សាស្រាវជ្រាវមុនដាក់ជូនក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ពិនិត្យសម្រេច
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ២.-**

សមាជិកក្រុមការងារចំពោះកិច្ចសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣.-**

នាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម ជាសេនាធិការឲ្យក្រុមការងារនេះសម្រាប់ភារកិច្ចដូចខាងក្រោម៖

- រៀបចំសំណុំឯកសារសម្រាប់ការប្រជុំរបស់ក្រុមការងារ
- រៀបចំលិខិតអញ្ជើញ និងរបៀបវារៈសម្រាប់កិច្ចប្រជុំតាមការកំណត់របស់ប្រធាន
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារ
- ធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់ក្រុមការងារ
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាន។

**ប្រការ៤.-**

ចំណាយរដ្ឋបាលលើការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារចំពោះកិច្ចសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាបន្ទុករបស់ ប.ស.ស.។

**ប្រការ៥.-**

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៤ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២១

**ជ.ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.**

**ប្រធាន**

**អ៊ិត សំហេង**